# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ
# ភ្នំពេញថ្មី ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០
# គស៊ូដើម្បីរកឃើញព្រះគ្រីស្ដ

**អត្ថបទទី១៖ អេសាយ ៦០,១-៦**

ប្រជាជាតិនានានាំគ្នាដើរទៅរកពន្លឺរបស់អ្នក ហើយស្ដេចទាំងឡាយក៏ដើរទៅរករស្មីដែលចាំងចេញពីអ្នកដែរ។ អស ៦០,៣

**អត្ថបទទី២៖ អេភេសូ ៣,២-៣ក.៥-៦**

ដោយសារដំណឹងល្អ សាសន៍ដទៃមានសិទ្ធិចូលរួមទទួលមត៌ក មានសិទ្ធិចូលរួមក្នុងព្រះកាយតែមួយ និងមានសិទ្ធិទទួលព្រះពរ តាមព្រះបន្ទូលសន្យារួមជាមួយសាសន៍អ៊ីស្រាអែល ក្នុងអង្គព្រះគ្រីស្ដយេស៊ូដែរ។ អភ ៣,៦

**ដំណឹងល្អ៖ ម៉ាថាយ ២,១-១២**

ព្រះមហាក្សត្ររបស់ជនជាតិយូដា ដែលទើបនឹងប្រសូតគង់នៅឯណា? មថ ២,២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ហោរាចារ្យជាតំណាងនៃគ្រប់ទិសក្នុងពិភពលោកទាំងមូល ដែលមកថ្វាយបង្គំដល់ព្រះយេស៊ូ បានធ្វើដំណើរពីចម្ងាយតាមផ្កាយ។ ផ្កាយនេះ ជាពន្លឺមួយយ៉ាងប្លែកនៅក្នុងភាពងងឹតនៃផ្ទៃមេឃ ណែនាំឲ្យគេទៅដល់ស្ដេចហេរ៉ូដ ពីស្ដេចហេរ៉ូដទៅដល់បេថ្លេហិមដែលជាកន្លែងមួយដែលព្រះសង្គ្រោះប្រសូត។ ផ្កាយនេះ បានណែនាំគេទៅដល់ក្រោលគោមួយសាមញ្ញធម្មតាដើម្បីថ្វាយបង្គំដល់ព្រះយេស៊ូដែលជាព្រះសង្គ្រោះ។

នៅពេលយើងមើលរបៀបដែលហោរាចារ្យបានធ្វើដំណើរដើរតាមផ្កាយ ដែលផ្កាយនេះបានណែនាំឲ្យគេទៅដល់កន្លែងមួយប្លែក គេស្វែងរកសុភមង្គល។ គេបានធ្វើដំណើរពីចម្ងាយដើម្បីទៅដល់ភូមិដ៏តូចមួយនៅស្រុកយូដា ដែលមានកូនង៉ែតម្នាក់ដែលគេថា "**នេះជាព្រះសង្គ្រោះ**" នេះជាសុភមង្គលដ៏ពិតប្រាកដ។ សម្រាប់យើងសព្វថ្ងៃ គោលបំណងនៃជីវិតគឺទៅរកសុភមង្គលពិតប្រាកដ **តើយើងទៅរកសុភមង្គលដ៏ពិតប្រាកដដោយរបៀបណា?** នៅផ្លូវត្រីគេគោរពលោកឪពុកយៀប គាត់ទទួលខុសត្រូវព្រះសហគមន៍នេះនៅឆ្នាំ១៩២៤ គាត់ស្លាប់នៅប្រទេសវៀតណាម នៅឆ្នាំ១៩៤៦។ ថ្ងៃនេះ យើងមានលោកឪពុកចាហ្គីឡង់ ដែលកំពុងរៀបចំស៊ើបអង្កេតដើម្បីទទួលស្គាល់លោកយៀបជាសន្តបុគ្គល។ គេជឿថា លោកយៀបនោះណែនាំឲ្យគេរកស៊ីបានច្រើន ហេតុនេះហើយរាល់ឆ្នាំនៅភូមិភាគកាន់ធើ ដែលជាភូមិភាគកំណើតរបស់គាត់ មាន

រាប់ម៉ឺននាក់ទាំងពុទ្ធបរិស័ទ ទាំងគ្រីស្តបរិស័ទ ទាំងអ្នកដែលអត់សាសនាទៅទីនោះដើម្បីសូមឲ្យលោកជួយគេរកស៊ីបាន។ នៅផ្លូវត្រីក្នុងភូមិភាគភ្នំពេញយើងក៏ដូចគ្នាដែរគេទៅយ៉ាងច្រើន លោកឪពុកនេះអត់បានធ្វើអ្វីអស្ចារ្យ ប៉ុន្តែគាត់បានលះបង់ចោលនៅក្នុងការបម្រើព្រះសហគមន៍ នៅក្នុងការស្រឡាញ់ព្រះសហគមន៍ រហូតដល់គេសម្លាប់គាត់។ **តើសុភមង្គលដ៏ពិតប្រាកដបានមកពីណា?** នេះជាសំណួរដែលយើងត្រូវតែមាន ថ្ងៃនេះហោរាចារ្យពិតមែនគាត់យកទ្រព្យសម្បត្តិថ្លៃៗណាស់ យកមាស យកធូប យកកំញាន គ្រឿងថ្លៃៗដើម្បីថ្វាយទៅព្រះជាម្ចាស់។ ប៉ុន្តែ គេបានថ្វាយបង្គំដោយយល់ថា ធ្វើដំណើរយ៉ាងឆ្ងាយនៅក្នុងការពិបាកដោយលះបង់ចោលយ៉ាងច្រើនដើម្បីរកឃើញព្រះយេស៊ូ។

នៅក្នុងជីវិតរបស់យើងដែលជាគ្រីស្តបរិស័ទ យើងត្រូវតែយល់ថានៅរាត្រីបុណ្យព្រះយេស៊ូប្រសូត យើងចូលទៅក្នុងអាថ៌កំបាំងនៃគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់មនុស្សយើង គឺព្រះជាម្ចាស់ចង់ឲ្យមនុស្សទទួលការសង្គ្រោះ ព្រះជាម្ចាស់ចង់ឲ្យយើងទទួលសុភមង្គលដ៏ពិតប្រាកដនៅលើផែនដីនេះ មុនទទួលសុភមង្គលអស់កល្បជានិច្ចនៅស្ថានបរមសុខ។ អាថ៌កំបាំងដ៏អស្ចារ្យពីព្រះយេស៊ូប្រសូត នេះជាមូលដ្ឋាននៃជំនឿរបស់យើងដើម្បីទៅរកសុភមង្គលនឹកឃើញព្រះយេស៊ូប្រសូត ណែនាំឲ្យយើងរកឃើញពន្លឺ និងពន្លឺនេះជាពន្លឺដែលណែនាំឲ្យយើងមានសុភមង្គលដ៏ពិតប្រាកដ។

នៅពេលយើងមើលរបៀបហោរាចារ្យ នៅពេលយើងមើលជីវិតរបស់យើងសព្វថ្ងៃ ដើម្បីរកឃើញសុភមង្គលៈ

**ទីមួយ យើងត្រូវការធ្វើដំណើរ** យើងមិនអាចអង្គុយយ៉ាងស្ងៀមស្ងាត់នៅក្នុងបន្ទប់តូច យើងត្រូវតែធ្វើដំណើររកសុភមង្គល ដែលជាដំណើរមួយនៅក្នុងដួងចិត្តរបស់យើង។ ហោរាចារ្យបានធ្វើដំណើរពីចម្ងាយពិតមែន លោកអាប្រាហាំបានចេញពីប្រទេសពីស្រុកកំណើតរបស់គាត់ដើម្បីដើរតាមព្រះជាម្ចាស់ពិតមែន។ យើងប្រហែលមិនធ្វើដំណើរពីភូមិមួយទៅភូមិមួយ ប៉ុន្តែយើងធ្វើដំណើរនៅក្នុងដួងចិត្តរបស់យើង ដើម្បីកែប្រែដួងចិត្តរបស់យើង ឲ្យយើងយល់ថាសុភមង្គលដ៏ពិតប្រាកដគឺជាអ្វី? យើងសម្លឹងមើលព្រះយេស៊ូ ចេះដំណើរជាមួយបងប្អូនដែលមានទុក្ខលំបាក ចេះបម្រើអ្នកក្រីក្រអស់ពីសមត្ថភាព ចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមកដើម្បីបង្កើតគ្រួសារមួយដោយស្រឡាញ់គ្នាពិតៗ។ យើងធ្វើដំណើរនៅក្នុងដួងចិត្តរបស់យើង កុំឲ្យយើងអង្គុយស្ងៀមស្ងាត់ កុំឲ្យយើងភ្លេចខ្លួន កុំឲ្យយើងដេកនៅក្នុងបន្ទប់ដោយមិនដឹងខ្លួនសម្រាប់ព្រះសហគមន៍ក៏ដូចគ្នាដែរ។

**ទីពីរ ការតស៊ូ** អត់មានការតស៊ូអត់មានការរីកចម្រើន គេបានតស៊ូច្រើននៅសម័យនោះធ្វើដំណើរពិបាកណាស់។ ពេលគេជួបស្ដេចហេរូដ គេយល់ថាស្ដេចហេរូដនេះមានគម្រោងការអត់ល្អ ហេតុនេះហើយពេលគេធ្វើដំណើរត្រលប់ទៅវិញ គេមិនទៅថ្វាយបង្គំស្ដេចហេរូដម្ដងទៀតទេ គេទៅតាមផ្លូវផ្សេងប្រហែលរឹតតែឆ្ងាយថែមទៀត គេបានតស៊ូដើម្បីរកឃើញព្រះយេស៊ូ។ យើងមិនអាចជោគជ័យ នៅក្នុងគោលដៅនៃជីវិតរបស់យើងប្រសិនបើយើងមិនតស៊ូ។ **តើជីវិតខ្ញុំមានគោលដៅអ្វីខ្លះ? តើខ្ញុំធ្វើដំណើរដូចម្ដេចដើម្បីទៅដល់គោលដៅនោះ? តើខ្ញុំតស៊ូរបៀបណាដើម្បីជោគជ័យ?**

**ទីបី ឲ្យយើងឡើងពីជំហ៊ានមួយទៅជំហ៊ានមួយ** ពីមួយឆ្នាំទៅមួយឆ្នាំ កុំឲ្យជីវិតរបស់យើងនៅស្ងួនស្ងៀមដដែល។ សមត្ថភាពរបស់យើង នៅក្នុងទំនាក់ទំនង នៅក្នុងការស្រឡាញ់ នៅក្នុងការជួយអ្នកដទៃ ចូលរួមអភិបូជា ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ កែប្រែចិត្តគំនិត ពីមួយឆ្នាំទៅមួយឆ្នាំឲ្យជីវិតរបស់យើងរីកចម្រើន។ យើងអាចធ្វើបាន លុះត្រាតែយើងតស៊ូនិងធ្វើដំណើរ កុំឲ្យយើងអង្គុយលើកៅអីអត់ដឹងខ្លួន។ ពេលយើងឃើញកូនង៉ែត យើងនឹកឃើញយ៉ូហានបាទីស្ទដែលម្ដាយសួរខ្លួនឯងថា **តើកូននេះទៅថ្ងៃអនាគតទៅជាយ៉ាងណា?** នេះជាសំណួរដែលគេសួរនៅពេលឃើញយ៉ូហានបាទីស្ទកើតមក។ នៅពេលម្ដាយកំពុងស្ដាប់ខ្ញុំទេសនា ប្រហែលម្ដាយគិតថា កូនខ្ញុំនៅថ្ងៃអនាគតរកសុភមង្គលយ៉ាងពិតប្រាកដ។ ឲ្យយើងធ្វើដូចម្ដេច ដើម្បីឲ្យជីវិតរបស់យើងរីកចម្រើនថែមទៀត នៅក្នុងអំណរ នៅក្នុងសេចក្ដីសុខ តាមហោរាចារ្យមកថ្វាយបង្គំដល់ព្រះយេស៊ូ។

សូមព្រះជាម្ចាស់ប្រទានពរឲ្យយើងទាំងអស់ ដើម្បីឲ្យនៅក្នុងបុណ្យព្រះយេស៊ូសម្ដែងឋានៈជាព្រះអង្គ យើងអាចមើលឃើញពន្លឺរបស់ព្រះអង្គនៅក្នុងដួងចិត្តរបស់យើង ចេញធ្វើដំណើរតស៊ូ និងរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃដើម្បីរកឃើញសុភមង្គលដ៏ពិតប្រាកដ។ អាម៉ែន៕